**មជ្ឈមណ្ឌលភីឌីភី**

**PDP-CENTER**

---

# បទបញ្ញត្តិ

# ស្តីពី

# ការប្រើប្រាស់យានយន្ត និងទោចក្រយានយន្ត

ដើម្បីគ្រប់គ្រងការប្រើប្រាស់យានយន្តនិងទោចក្រយានយន្តគ្រប់ប្រភេទមជ្ឈមណ្ឌលភីឌីភីឲ្យមានប្រសិទ្ធភាព មជ្ឈមណ្ឌលភីឌីភីសំរេចដាក់ចេញបទបញ្ញត្តិដូចខាងក្រោម:

១.រាល់យានយន្ត និងទោចក្រយានយន្តត្រូវរក្សាទុកនៅការិយាល័យមជ្ឈមណ្ឌលភីឌីភីនៅតាមរាជាធានី/ខេត្តនីមួយៗមិនអនុញ្ញាតអោយកទៅទុកនៅផ្ទះរបស់បុគ្គលិកណាម្នាក់

ឡើយ។

២.ការយកទៅទុកនៅផ្ទះបានលុះត្រាតែមានការសុំអនុញ្ញាតពីរដ្ឋបាលមជ្ឈមណ្ឌលភីឌីភីនៅស្នាក់ការកណ្តាលរាជធានីភ្នំពេញ។ការយកទៅទុកនៅផ្ទះនេះក្នុងខណៈដែលទីស្នាក់ការត្រូវបានពិនិត្យឃើញថាគ្មានសុវត្ថិភាព ឬទីស្នាក់ការគ្មានកន្លែងដាក់ ឬបុគ្គលិកត្រូវចេញដំណើរទៅធ្វើការងាររបស់មជ្ឈមណ្ឌលភីឌីភីពីព្រលឹម។

៣.ការយកយានយន្ត ទោចក្រយានយន្តចេញពីការិយាល័យត្រូវចុះចូលក្នុងសៀវភៅបន្ទុកនៃការប្រើប្រាស់យានយន្ត ឬទោចក្រយានយន្តនូវម៉ោង ថ្ងៃខែឆ្នាំនៃការយកយានយន្ត ឬទោចក្រយានយន្តចេញព្រមទាំងចុះហត្ថលេខាពីអ្នកដែលយកទៅប្រើប្រាស់។ពេលយក

យានយន្ត ឬទោចក្រយានយន្តមកវិញក៏ត្រូវចុះម៉ោង ថ្ងៃខែឆ្នាំនិងហត្ថលេខាអ្នកដែលបានប្រើប្រាស់។

៤.ការប្រើយានយន្ត ឬទោចក្រយានយន្តត្រូវមានធានារ៉ាប់រង។ ចំពោះការប្រើប្រាស់ដោយគ្មានធានារ៉ាប់រង ឬធានារ៉ាប់រងហួសកំណត់មិនត្រូវបានអនុញ្ញាតឡើយ។

៥.ការយកយានយន្តទៅប្រើប្រាស់ជាលក្ខណៈបុគ្គលដែលជាបុគ្គលិកមជ្ឈមណ្ឌលភីឌីភីត្រូវបានអនុញ្ញាតតែក្នុងកាលៈទេសៈដែលមានពិធីផ្សេងៗ ឬការរវល់ចាំបាច់នានាប៉ុណ្ណោះ។ ការខ្ចីយកទៅប្រើប្រាស់នេះអាចធ្វើទៅបានតែក្នុងកាលៈទេសៈដែលយានយន្ត ឬទោចក្រយានយន្តនៅទំនេរប៉ុណ្ណោះ។ ក្នុងការយកទៅប្រើប្រាស់នេះបើមានខូចខាតដោយប្រការណាមួយថ្លៃជួសជុលជាបន្ទុកទាំងស្រុងរបស់អ្នកដែលខ្ចីយកទៅប្រើប្រាស់នោះ។

៦.ផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុរបស់មជ្ឈមណ្ឌលភីឌីភីជាអ្នកគ្រប់គ្រងរាល់យាន និងទោចក្រយានយន្តទាំងអស់នោះ។

៧.បទបញ្ញត្តិនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី...ខែធ្នូ ឆ្នាំ២០១១

ជ.មជ្ឈមណ្ឌលភីឌីភី

ប្រធាន

យង់ គិមអេង